សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
**LICADHO**
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

#16 Street 99, P. O. Box 499
Phnom Penh, Cambodia
Tel: (855) 23 360 965 / 364 901
Fax: (855) 23 360 965 / 217 626
or +1 (815) 550 4474
Email: contact@licadho.org
Web Site: http://www.licadho.org/

# របាយការណ៍លីកាដូ ២០០៨: ប្រព័ន្ធសារព័ត៌មានត្រូវបានរំខានដោយ សេចក្តីភ័យខ្លាច និងអំពើពុករលួយ

*ថ្ងៃទី២ ខែឧសភា ២០០៨*

ប្រព័ន្ធសារព័តិមានក្នុងប្រទេសកម្ពុជាត្រូវបានគេពិពណ៌នាជាញឹកញាប់ថាជាប្រព័ន្ធសារព័តិមានមួយ ដែលមានសេរីភាពបំផុតនៅក្នុងតំបន់ តែការពិត អ្នកសារព័តិមានជាច្រើនបាននិយាយថាជាបរិយាកាសមួយ ដែលទំនុកចិត្តត្រូវបានធ្លាក់ចុះដោយសារតែភាពលំអៀងផ្នែកនយោបាយ សេចក្តីភ័យក្លាយ និងអំពើពុករលួយ។

ប្រព័ន្ធសារព័តិមានក្នុងប្រទេសកម្ពុជាភាគច្រើនមាននិន្នាការទៅរកគណៈបក្សនយោបាយ ហើយភាគច្រើនមានទំនោរទៅរកគណៈបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។ ការសូកប៉ាន់គឺជារឿងធម្មតាដែលគេមិនចាត់ទុកថាជាអំពើពុករលួយទេ។ ការបញ្ឈប់ការចេញផ្សាយជាផ្លូវការនៅតែមាន និងការបញ្ឈប់មិនអោយចេញផ្សាយនូវបញ្ហាផ្ទាល់ខ្លួន បានរាលដាលទូទាំងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា។

ការស្ទង់មតិថ្មីមួយបង្ហាញថាអ្នកសារព័តិមានកម្ពុជាជាច្រើនត្រូវបានវាយប្រហារ (ផ្នែករាងកាយ ឬផ្នែកផ្លូវច្បាប់) ហើយពួកគាត់ភាគច្រើនមានអារម្មណ៍ថាងាយរងគ្រោះ។ ការគំរាមកំហែង និងការភ័យខ្លាចមានឥទ្ធិពលដោយផ្ទាល់លើការងាររបស់ពួកគេ ហើយសេចក្តីរាយការណ៍របស់ពួកគេក៏មានឥទ្ធិពលដោយផ្ទាល់លើទស្សនាទានរបស់សាធារណៈជនទូទៅអំពីប្រទេសជាតិរបស់ពួកគេ ជាពិសេសនៅក្នុងកំឡុងពេលបោះឆ្នោត។

កញ្ញា ណាលី ពីឡូក នាយិកាអង្គការលីកាដូបានមានប្រសាសន៏ថា "ការបន្តដាក់ទណ្ឌកម្មជាបទឧក្រិដ្ឋចំពោះអ្នកសារព័តិមាន ចាំបាច់ត្រូវតែបំបាត់ចោល រួមទាំងការផ្តល់ព័តិមានក្លែងក្លាយ និងកង្វះខាតព័តិមានផងដែរ ដើម្បីធានាឱ្យមានបរិយាកាសរួចផុតពីគំនាបនយោបាយ លើប្រព័ន្ធសារព័តិមានអោយមានវិសាលភាពលើបញ្ហារសើប និង បញ្ហាសំខាន់ៗដទៃទៀតដែលប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជា"។

ខណៈពេលដែលអ្នកសារព័តិមានមួយចំនួនគឺជាជនរងគ្រោះដោយប្រព័ន្ធនេះ ហើយអ្នកខ្លះជាផ្នែកនៃបញ្ហានេះ អ្នកសារព័តិមានកម្ពុជាជាច្រើនប្រាថ្នាចង់ឱ្យមានសស្ថានភាពផ្សេងៗគ្នា ។ពួកគេត្អូញត្អែរពីការទទួលបានប្រាក់ បៀវត្សរ៍តិចតួច និងការគាបសង្កត់ដើម្បីឱ្យស្របទៅតាមភាពលំអៀងផ្នែកនយោបាយ។ តួរលេខគួរអោយភ្ញាក់ផ្អើលមួយបង្ហាញ ថា ៨៥ %នៃអ្នកសារព័តិកម្ពុជាបានចាត់ទុកខ្លួនឯងជា "អ្នកការពារសិទ្ធិមនុស្ស" ។

លីកាដូ

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

LICADHO

#16 Street 99, P. O. Box 499
Phnom Penh, Cambodia
Tel: (855) 23 360 965 / 364 901
Fax: (855) 23 360 965 / 217 626
or +1 (815) 550 4474
Email: contact@licadho.org
Web Site: http://www.licadho.org/

មានការរកឃើញខ្លះនៅក្នុងរបាយការណ៍ថ្មីមួយរបស់អង្គការលីកាដូ ដែលមានចំណងជើងថា "Reading Between the Line: តើនយោបាយ ហិរញ្ញវត្ថុ និងសេចក្តីភ័យខ្លាចត្រួតត្រាលើប្រព័ន្ធសារព័ត៌មានក្នុងប្រទេសកម្ពុជាមានដោយរបៀបណានោះ" ត្រូវបានបោះពុម្ពដើម្បីអបអរសាទរទិវាសេរីភាពអ្នកសារព័ត៌មានពិភពលោក នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨។

លោកស្រីវេជ្ជ. ពុង ឈីវកេក ប្រធានអង្គការលីកាដូ បានមានប្រសាសន៍ថា "នៅតែមានសង្ឃឹមនៅឡើយទេ ក្នុងខណៈដែលអ្នកសារព័ត៌មានភាគច្រើនសំដែងនូវឆន្ទៈ ក្នុងការអនុវត្តការងាររបស់ពួកគេប្រកបដោយក្រមសីលធម៌ មិនលំអៀង និង ប្រកបដោយវិជ្ជាជីវៈ" ។

របាយការណ៍ ៧២ទំព័រនេះបរិយាយពីប្រព័ន្ធសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាតាមរយៈ ទស្សនវិស័យសិទ្ធិមនុស្ស។ របាយការណ៍នេះផ្តល់នូវទិដ្ឋភាពទូទៅពីបរិយាកាសប្រព័ន្ធសារព័ត៌មាន និងគ្របដណ្តប់បញ្ហាមួយចំនួន ដូចជា ភាពជាម្ចាស់លើប្រព័ន្ធសារព័ត៌មាន ភាពលំអៀងផ្នែកនយោបាយ ការទទួលព័ត៌មាន ការបញ្ឈប់ការចេញផ្សាយ ការវាយប្រហារ និងការគំរាមកំហែងលើប្រព័ន្ធសារព័ត៌មាន។

របាយការណ៍នេះក៏បានដាក់បញ្ចូលនូវលទ្ធផលនៃការស្ទង់មតិអ្នកសារព័ត៌មានកម្ពុជាចំនួន ១៤១នាក់ ទូទាំងប្រទេសកម្ពុជា (ជាការស្ទង់មតិពីប្រព័ន្ធសារព័ត៌មានយ៉ាងទូលំទូលាយមួយដែលមិនធ្លាប់មាន) ព្រមទាំងទស្សនៈរបស់អ្នកពាក់ព័ន្ធសារព័ត៌មានសំខាន់ៗដទៃទៀត។

**សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនង :**

**លោកស្រីវេជ្ជ. ពុង ឈីវកេក ប្រធានអង្គការលីកាដូ តាមរយៈទូរស័ព្ទ ០១២ ៩៤០ ៦៤៥**